# អត្ថប្រយោជន៍ Medi-Cal ដែលមានការធានារ៉ាប់រងពី Anthem

## សេវាអ្នកជំងឺក្រៅ (រថយន្តសង្គ្រោះ)

*កម្មវិធី ការថែទាំបណ្តោះអាសន្នក្រោយពេលសម្រាលកូន ត្រូវបានជំនួសដោយកម្មវិធីថ្មីឈ្មោះ*
*ការថែទាំក្រោយពេលសម្រាលកូន ។*

## កម្មវិធី ការថែទាំក្រោយពេលសម្រាលកូន

កម្មវិធី ការថែទាំក្រោយពេលសម្រាលកូន ផ្តល់ជូនការធានារ៉ាប់រងបន្ថែមសម្រាប់សមាជិករបស់ Medi-Cal ក្នុងអំឡុងពេលទាំងមានផ្ទៃពោះ និងបន្ទាប់ពីសម្រាលហើយ។

កម្មវិធី ការថែទាំក្រោយពេលសម្រាលកូន បន្ថែមការធានារ៉ាប់រងដោយ Anthem សម្រាប់រយៈពេលរហូតដល់ទៅ 12 ខែបន្ទាប់ពីពេលបញ្ចប់នៃការមានផ្ទៃពោះ ដោយមិនគិតពីប្រាក់ចំណូល សញ្ជាតិ ឬស្ថានភាពអន្តោប្រវេសន៍នោះទេ ហើយមិនចាំបាច់មានវិធានការបន្ថែមនោះទេ។

## ការពិនិត្យលំដាប់នៃហ្សែនបន្តត្រកូលទាំងស្រុងក្នុងរយៈពេលខ្លី (Rapid Whole Genome Sequencing)

ការពិនិត្យលំដាប់នៃហ្សែនបន្តត្រកូលទាំងស្រុងក្នុងរយៈពេលខ្លី (Rapid Whole Genome Sequencing, rWGS) រួមបញ្ចូលទាំងការពិនិត្យលំដាប់លក្ខណៈបុគ្គល (individual sequencing) ការពិនិត្យលំដាប់បីភាគ (trio sequencing) សម្រាប់ឪពុកម្តាយម្នាក់ ឬឪពុកម្តាយច្រើននាក់ និងទារក
របស់ពួកគេ និងការពិនិត្យលំដាប់ដែលប្រើរយៈពេលខ្លីខ្លាំង (ultra-rapid sequencing) គឺជាអត្ថប្រយោជន៍ ដែលមានការរ៉ាប់រងសម្រាប់សមាជិក Medi-Cal ដែលមានអាយុមួយឆ្នាំ ឬក្មេងជាងនេះ ហើយកំពុង
ទទួលបានសេវាពីមន្ទីរពេទ្យសម្រាប់អ្នកស្នាក់ព្យាបាលក្នុងផ្នែកសង្គ្រោះជំងឺធ្ងន់។ rWGS គឺជាវិធីសាស្ត្រ
ដែលកំពុងលេចឡើងសម្រាប់ការធ្វើរោគវិនិច្ឆ័យស្ថានភាពសុខភាពយ៉ាងទាន់ពេលវេលាដើម្បីជះឥទ្ធិពលលើការថែទាំផ្នែក ICU របស់កុមារ ដែលមានអាយុមួយឆ្នាំ ឬក្មេងជាងនេះ។ ប្រសិនបើអ្នកមានគ្រប់លក្ខណៈ
សម្បត្តិសម្រាប់សេវា California Children’s Services (CCS) នោះ CCS អាចនឹងទទួលខុសត្រូវចំ

ពោះការធានារ៉ាប់រងលើការស្នាក់នៅមន្ទីរពេទ្យ និងការពិនិត្យ rWGS ។